# ការអនុវត្តន៍ល្អ
## សញ្ញាបំពង់ពន្លត់អគ្គីភ័យ

**រោងចក្រ កាន់តែប្រសើរ នៅកម្ពុជា**

បំពង់ពន្លត់អគ្គីភ័យ ចាំបាច់ត្រូវដាក់នៅទីកន្លែងដែលងាយស្រួលមើលឃើញ និងយកបានក្នុងករណីមានគ្រោះអាសន្នកើតឡើង ។ កម្មករ ត្រូវមានលទ្ធភាពឃើញវាពីចំងាយ និងអាចទៅយកវាបានយ៉ាងងាយស្រួល ។ មិនត្រូវដាក់កេះតវ៉ាន់ និងវត្ថុផ្សេងៗបាំងបំពង់ពន្លត់អគ្គីភ័យ និងសំភារៈសុវត្ថិភាពអគ្គីភ័យឡើយ ។ សូមពិចារណាលើការអនុវត្តន៍ល្អខាងក្រោម សំរាប់រោងចក្រដែលមានសុវត្ថិភាព និងមានប្រសិទ្ធភាពបំផុត ។ សូមមើលផងដែរនូវសេចក្តីណែនាំការអនុវត្តន៍ល្អស្តីពី សុវត្ថិភាពអគ្គីភ័យ និងអ្នកពន្លត់អគ្គីភ័យ ។

### ការអនុវត្តន៍ល្អសំរាប់សញ្ញាពន្លត់អគ្គីភ័យ

លាបពណ៌ក្រហមលើជញ្ជាំង ឬលើសរសរដើម្បីអោយមើលឃើញច្បាស់ (រូបភាពទី១) ។

ជំរើសម្យ៉ាងទៀត ដាក់ផ្លាកសញ្ញាពណ៌ក្រហមរាងត្រីកោណជាប់ជញ្ជាំង មានកំពស់ផុតពីក្បាល (រូបភាពទី២) ។

ធានាថា បំពង់ពន្លត់អគ្គីភ័យ ងាយស្រួលយកគ្រប់ពេលទាំងអស់ ។ កុំដាក់ប្រអប់ ឬវត្ថុនៅបាំងពីមុខបំពង់ពន្លត់អគ្គីភ័យ (រូបភាពទី៣) ។

ត្រួតពិនិត្យមើលថា មានការបំពាក់ប្រភេទបំពង់ពន្លត់អគ្គីភ័យត្រឹមត្រូវ ហើយធានាថា បំពង់ពន្លត់អគ្គីភ័យត្រូវបានបិទផ្លាកសញ្ញាសំគាល់ត្រឹមត្រូវ ។

ធានាថា បំពង់ពន្លត់អគ្គីភ័យប្រើការបាន តាមរយៈការធ្វើការពិនិត្យត្រឹមត្រូវជាប្រចាំ ។ ដាក់ផ្លាកសញ្ញាចំណាំលើបំពង់ពន្លត់អគ្គីភ័យ ដើម្បីបង្ហាញពីពេលពិនិត្យចុងក្រោយ ។



រូបភាពទី១


រូបភាពទី២


រូបភាពទី៣

### អត្ថប្រយោជន៍:

- ✓ បង្ហាញពីទស្សនៈល្អនៃកន្លែងធ្វើការងារប្រកបដោយការទទួលខុសត្រូវ
- ✓ នៅពេលមានគ្រាអាសន្ន កម្មករអាចរកឃើញសំភារៈពន្លត់អគ្គីភ័យបានយ៉ាងងាយ
- ✓ ឆ្លើយតបយ៉ាងឆាប់រហ័ស ដើម្បីកាត់បន្ថយឱកាសបង្ករគ្រោះថ្នាក់អគ្គីភ័យធ្ងន់ធ្ងរចំពោះមនុស្ស ឬទ្រព្យសម្បត្តិ ដែលអាចជួយសង្គ្រោះជីវិតមនុស្ស និងសន្ទំរថវិកា

### តាមរបៀបណា:

- ✓ កំណត់ទីតាំងសមស្របសំរាប់បំពង់ពន្លត់អគ្គីភ័យ ដែលងាយស្រួលយកប្រើនៅពេលមានអគ្គីភ័យ
- ✓ ដាក់កន្លែងដែលងាយស្រួលចំណាំ មានសញ្ញាបង្ហាញច្បាស់នៅពីលើបំពង់ពន្លត់អគ្គីភ័យ ឬលាបពណ៌ក្រហម (សូមមើលរូបថត)

### តំលៃ:

**$**

- $ តំលៃទាប
- $$ តំលៃមធ្យម
- $$$ តំលៃខ្ពស់

អង្គការ ពលកម្ម អន្តរជាតិ

ប្រសិនបើលោកអ្នកមានសំនួរ សូមទាក់ទងមកអង្គការពលកម្មអន្តរជាតិតាមរយៈអ៊ីម៉ែល betterfactories@ilo.org